ធនាគារជាតិ នៃ កម្ពុជា

លេខ.........................................................

# សុន្ទរកថា

## ឯកឧត្តម ជា ចាន់តូ ទេសាភិបាលធនាគារជាតិនៃកម្ពុជា
## ថ្លែងក្នុងឱកាសបើកសន្និបាតបូកសរុបលទ្ធផលការងារឆមាសទី១
## និងទិសដៅការងារឆមាសទី២ ឆ្នាំ២០១៤ របស់ធនាគារជាតិនៃកម្ពុជា

រាជធានីភ្នំពេញ ថ្ងៃទី២ ខែសីហា ឆ្នាំ២០១៤

សូមគោរព :

- គណៈអធិបតី
- លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញាទាំងអស់ ជាទីមេត្រី!

ថ្ងៃនេះ ខ្ញុំមានក្តីសោមនស្សរីករាយជាអតិបរមា ដោយបានមកចូលរួមក្នុងសន្និបាតបូកសរុបលទ្ធផលការងារឆមាសទី១ និងទិសដៅការងារឆមាសទី២ ឆ្នាំ២០១៤ របស់ធនាគារជាតិនៃកម្ពុជា ជាមួយលោកជំទាវ ឯកឧត្តម លោក លោកស្រី និងនាងកញ្ញា នាពេលនេះ ។ ជារៀងរាល់ឆ្នាំ យើងតែងតែប្រារព្ធពិធីនេះឡើងដើម្បីផ្សព្វផ្សាយនិងអបអរសាទរសមិទ្ធផលការងាររបស់ធនាគារជាតិនៃកម្ពុជាដែលសម្រេចបាន ក៏ដូចជាផ្តល់ឱកាសដល់មន្ត្រីបុគ្គលិកទាំងនៅស្នាក់ការកណ្តាលនិងសាខារាជធានី-ខេត្ត បានជួបប្រាស្រ័យទាក់ទងគ្នានិងផ្លាស់ប្តូរបទពិសោធន៍គ្នាដោយផ្ទាល់ ។ ចាប់តាំងពីធនាគារជាតិនៃកម្ពុជាត្រូវបានបង្កើតឡើងវិញនៅក្រោយថ្ងៃមហាជ័យជំនះ ៧ មករា ១៩៧៩ មានរយៈពេល ៣៥ឆ្នាំហើយ ។ ក្នុងនាមអាជ្ញាធររូបិយវត្ថុជាតិនៃប្រទេសកម្ពុជា ធនាគារជាតិនៃកម្ពុជាបានបំពេញមុខងារនិងភារកិច្ចក្នុងការរក្សាស្ថិរភាពថ្លៃ និងរួមចំណែកពង្រឹងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ប្រកបដោយប្រសិទ្ធភាព ។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមថ្លែងអំណរគុណនិងកោតសរសើរយ៉ាងខ្លាំង ចំពោះមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជាគ្រប់ជាន់ថ្នាក់ទាំងអស់ ដែលបានខិតខំបំពេញការងារប្រកបដោយស្មារតីទទួលខុសត្រូវ កសាងសមិទ្ធផលជាច្រើនជូនធនាគារជាតិនៃកម្ពុជា និងរួមចំណែកអភិវឌ្ឍប្រព័ន្ធធនាគារនៅកម្ពុជា ឱ្យមានការរីកចម្រើនប្រកបដោយសុវត្ថិភាព និងប្រសិទ្ធភាព ស្របតាមយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុរយៈពេលវែងរបស់រាជរដ្ឋាភិបាល ។



ប្រអប់សំបុត្រលេខ ២៥, ផ្លូវលេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

- គណៈអធិបតី
- លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ជាទីមេត្រី!

ខ្ញុំសូមជម្រាបថា សន្និបាតរបស់យើងថ្ងៃនេះរៀបចំឡើងក្នុងគោលបំណងផ្សព្វផ្សាយពីលទ្ធផលការងារសំខាន់ៗ របស់ធនាគារជាតិនៃកម្ពុជានៅឆមាសទី១ ឆ្នាំ២០១៤ ដូចតទៅ ៖

## I/- សភាពការណ៍ទូទៅនៃសេដ្ឋកិច្ចពិភពលោក តំបន់ និងសេដ្ឋកិច្ចកម្ពុជា

នៅឆមាសទី១ ឆ្នាំ២០១៤ នេះ តាមការវាយតម្លៃរបស់អង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) បញ្ជាក់ថា សេដ្ឋកិច្ចពិភពលោកនៅតែបន្តងើបឡើងជាវិជ្ជមាន ទោះបីជាល្បឿនកំណើនបានថមថយបន្តិច នៅត្រីមាសទី១ ដោយសារឥទ្ធិពលនៃកត្តាធម្មជាតិមួយចំនួនបានប៉ះពាល់ដល់ការវិនិយោគនិងការប្រើប្រាស់នៅសហរដ្ឋអាមេរិកនិងប្រទេសចិន ក៏ដោយ ។ សន្ទុះកំណើនសេដ្ឋកិច្ចសហរដ្ឋអាមេរិក គួបផ្សំនឹងកំណើនសេដ្ឋកិច្ចនៃសេដ្ឋកិច្ចតំបន់អឺរ៉ូ បានធ្វើឱ្យសេដ្ឋកិច្ចប្រទេសអភិវឌ្ឍន៍បន្តមានថាមភាព និងក្លាយជាកម្លាំងចលករសម្រាប់គាំទ្រកំណើនសេដ្ឋកិច្ចសកល និងកំណើនតម្រូវការខាងក្រៅសម្រាប់ប្រទេសកំពុងងើបឡើង ដែលកំពុងប្រឈមនឹងភាពទន់ខ្សោយនៃតម្រូវការក្នុងស្រុក ។

ចំណែកឯ នៅតំបន់អាស៊ីវិញ កំណើនសេដ្ឋកិច្ចនៅតែបន្តកើនឡើង ស្របតាមនិន្នាការសេដ្ឋកិច្ចសកល និងនៅតែដើរតួនាទីសំខាន់ជាក្បាលម៉ាស៊ីននៃកំណើនសេដ្ឋកិច្ចសកល ហើយរំពឹងថា អាចរក្សាកំណើនបានខ្ពស់ ៦,៧% នៅឆ្នាំ២០១៤ នេះ។ ទន្ទឹមនេះ ស្ថានភាពហិរញ្ញវត្ថុសកលបានវិលមករកស្ថានភាពនឹងនរល្អបង្គួរឡើងវិញ ដោយសារមូលធនបន្តហូរចូលសន្សឹមៗទៅក្នុងសេដ្ឋកិច្ចប្រទេសកំពុងងើបឡើង ទោះបីជាមានការកាត់បន្ថយការចាក់បញ្ចូលទុនទៅក្នុងសេដ្ឋកិច្ចដោយធនាគារកណ្តាលសហរដ្ឋអាមេរិក ចាប់ពីដើមឆ្នាំនេះក៏ដោយ។

ស្ថិតក្នុងស្ថានអំណោយផលនៃសេដ្ឋកិច្ចសកល គួបផ្សំនឹងការរក្សាបាននូវស្ថិរភាពនយោបាយ សេដ្ឋកិច្ចកម្ពុជាបានបន្តកើនឡើងក្នុងល្បឿនមួយគួរឱ្យកត់សម្គាល់ ។ សូចនាករម៉ាក្រូសេដ្ឋកិច្ចសំខាន់ៗ បានបន្តបង្ហាញសញ្ញាល្អប្រសើរ ដោយការនាំចេញ វិស័យទេសចរណ៍ និងកសិកម្ម មានកំណើនរឹងមាំ ហើយវិស័យអចលនទ្រព្យនិងសំណង់បានងើបឡើងជាលំដាប់ ។ ផ្អែកលើស្ថានភាពល្អប្រសើរនេះ រាជរដ្ឋាភិបាលបានព្យាករដោយសុទិដ្ឋិនិយមថា សេដ្ឋកិច្ចកម្ពុជានឹងរក្សាបាននូវអត្រាកំណើនប្រមាណ ៧% នៅឆ្នាំ២០១៤ នេះ ។ កំណើននេះគាំទ្រដោយវិស័យកសិកម្មកើនឡើង ៤,៥%វិស័យឧស្សាហកម្ម ៨,៩% និងវិស័យសេវាកម្ម ព្រមទាំងការកើនឡើងនៃវិស័យទេសចរណ៍ កាត់ដេរ និងវិនិយោគផ្ទាល់បរទេស គួបផ្សំនឹងការអនុវត្តគោលនយោបាយត្រឹមត្រូវរបស់រាជរដ្ឋាភិបាល

ក្នុងការធ្វើពិពិធកម្មវិស័យផលិតកម្មរបស់រាជរដ្ឋាភិបាលទៅលើវិស័យអាទិភាព ដូចជាវិស័យកសិកម្ម និងពិពិធកម្មទីផ្សារនាំចេញផង ពិតជាបានរួមចំណែកគាំទ្រដល់ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងជំរុញកំណើនសេដ្ឋកិច្ចជាតិ ។

ទន្ទឹមនេះ ក្នុងនាមជាអាជ្ញាធររូបិយវត្ថុ ធនាគារជាតិនៃកម្ពុជាបានរួមចំណែកយ៉ាងសកម្មក្នុងការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច តាមរយៈការបន្តអនុវត្តគោលនយោបាយរូបិយវត្ថុ និងគោលនយោបាយប្តូរប្រាក់ប្រកបដោយភាពទន់ភ្លន់និងប្រុងប្រយ័ត្ន ផ្អែកលើវឌ្ឍនភាពនៃសកម្មភាពសេដ្ឋកិច្ចជាតិ និងបម្រែបម្រួលនៃសេដ្ឋកិច្ចពិភពលោក ដោយរក្សាបាននូវស្ថិរភាពថ្លៃនិងតម្លៃប្រាក់រៀល។

## II/- សមិទ្ធផលការងារសំខាន់ៗដែលធនាគារជាតិនៃកម្ពុជាសម្រេចបាន

ដើម្បីរួមចំណែកពង្រឹងស្ថិរភាពប្រព័ន្ធហិរញ្ញវត្ថុនិងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ឆ្ពោះទៅគាំទ្រការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ប្រកបដោយចីរភាព ស្របតាមកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ធនាគារជាតិនៃកម្ពុជាបានខិតខំបំពេញតួនាទីរបស់ខ្លួន ក្នុងការរក្សាស្ថិរភាពថ្លៃប្រកបដោយប្រសិទ្ធភាព ដោយរក្សាបាននូវស្ថិរភាពនៃតម្លៃប្រាក់រៀល និងអត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិក និងគ្រប់គ្រងអត្រាអតិផរណាឱ្យមានកម្រិតទាប ប្រែប្រួលក្នុងកម្រិតមួយអាចគ្រប់គ្រងបាន ។ តាមរយៈការអនុវត្តគោលនយោបាយរូបិយវត្ថុដោយប្រុងប្រយ័ត្ន ជារួម ស្ថានភាពម៉ាក្រូសេដ្ឋកិច្ចនៅតែរក្សាស្ថិរភាពល្អប្រសើរ សម្រាប់គាំទ្រដល់កំណើនសេដ្ឋកិច្ចជាតិ ។

សមិទ្ធផលទាំងនេះអាចឆ្លុះបញ្ចាំងតាមរយៈសូចនាករសំខាន់ៗ ដូចខាងក្រោម ៖

១)- កត្តារូបិយវត្ថុ និងភាពស៊ីជម្រៅផ្នែកហិរញ្ញវត្ថុ : នៅក្នុងឆមាសទី១ ឆ្នាំ២០១៤នេះ តម្លៃប្រាក់រៀលបន្តមានស្ថិរភាពល្អប្រសើរ ដោយប្រែប្រួលក្នុងរង្វង់ ៤.០០០រៀល ក្នុងមួយដុល្លារអាមេរិក ។ ចំណែកអតិផរណារួមឆ្នាំលើឆ្នាំ នាដំណាច់ឆមាសទី១នេះ ស្មើនឹង ៤,២% ប៉ុណ្ណោះ ។ ជារួម អតិផរណាត្រូវបានរក្សាក្នុងកម្រិតទាប ដែលជាកម្រិតមួយអាចគ្រប់គ្រងបាន ។ រូបិយវត្ថុទូទៅ (M2) មានកំណើនឆ្នាំលើឆ្នាំ ១៥% ដោយភាពស៊ីជម្រៅនៃវិស័យហិរញ្ញវត្ថុមានកម្រិតប្រមាណ ៥៦% នៅខែមិថុនា ឆ្នាំ២០១៤ ធៀបនឹង ៥៣% នាគ្រាដូចគ្នានៅឆ្នាំមុន ។ កត្តានេះបានឆ្លុះបញ្ចាំងពីតួនាទីនៃវិស័យធនាគារដែលកាន់តែមានសារៈសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ។ ទុនបម្រុងអន្តរជាតិដុល បានកើនឡើងរហូតដល់ ៤.៩០០លានដុល្លារអាមេរិក កើនឡើង ២០% ធៀបនឹងឆមាសទី១ ឆ្នាំ២០១៣ ដែលអាចធានាការនាំចូលបានចំនួនប្រមាណ ៤ខែ ដែលជាកម្រិតខ្ពស់សមស្របចំពោះ

ប្រទេសកំពុងអភិវឌ្ឍន៍ ។ ការគ្រប់គ្រងទុនបម្រុងត្រូវបានអនុវត្តដោយប្រុងប្រយ័ត្ន ស្របតាមភាពរឹងមាំនៃមូលដ្ឋានសេដ្ឋកិច្ចជាតិ ។

ក្រៅពីការចូលរួមពង្រឹងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ធនាគារជាតិនៃកម្ពុជាបានរួមចំណែកអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុរយៈពេលវែងរបស់រាជរដ្ឋាភិបាល ហើយសម្រេចបានលទ្ធផលល្អប្រសើរ ដូចខាងក្រោម ៖

២)- **វិស័យធនាគារ** : វិស័យនេះមានការអភិវឌ្ឍនិងរីកចម្រើនគួរឱ្យកត់សម្គាល់ និងបានដើរតួនាទីកាន់តែសំខាន់ក្នុងការរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចជាតិ ។ ផ្នែកវិសាលភាពគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅតែបន្តពង្រីកបណ្តាញប្រតិបត្តិការ តាមរយៈការបើកសាខានៅតាមរាជធានី-ខេត្ត ការិយាល័យតំណាង និងដាក់ឱ្យប្រើប្រាស់ម៉ាស៊ីនដកប្រាក់ដោយស្វ័យប្រវត្តិបន្ថែម ។ គិតត្រឹមឆមាសទី១នេះ ធនាគារពាណិជ្ជមានចំនួន៣៥ ធនាគារឯកទេសចំនួន៩ ការិយាល័យតំណាងធនាគារបរទេសចំនួន៦ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន៤០ ក្នុងនោះមានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន៧ ត្រូវបានអនុញ្ញាតឱ្យទទួលប្រាក់បញ្ញើពីសាធារណជន ប្រតិបត្តិករឥណទានជនបទដែលបានចុះបញ្ជីចំនួន៣៥ ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុចំនួន៣ ក្រុមហ៊ុនក្រេឌីតប្យូរ៉ូកម្ពុជា និងអ្នកដំណើរការតតិយភាគី៤ និងម៉ាស៊ីន ATM ចំនួន ៨៣០កន្លែង នៅទូទាំងប្រទេស ។

ចំពោះទំហំប្រតិបត្តិការវិញ គិតត្រឹមឆមាសនេះ ប្រាក់បញ្ញើក្នុងប្រព័ន្ធធនាគារ បានកើនឡើងប្រមាណ ១៣% និងឥណទានដល់វិស័យឯកជនបានកើនឡើង ២៨% ចំនួនអ្នកទទួលបានឥណទានមានជាង ២លាននាក់ កើនឡើង ២០% ហើយចំនួនអ្នកដាក់ប្រាក់បញ្ញើមានជិត ៣លាននាក់ កើនឡើង ១៨% ធៀបនឹងគ្រាដូចគ្នានៅឆ្នាំ២០១៣ ។ ការវិវត្តរីកចម្រើននេះគួបផ្សំនឹងការអនុវត្តវិធានការប្រុងប្រយ័ត្នផងនោះ បានធ្វើឱ្យឥណទានមិនដំណើរការ (NPL) ថយចុះមកនៅកម្រិត ២,៦% ដែលបង្ហាញពីគុណភាពល្អនៃទ្រព្យសកម្មរបស់វិស័យធនាគារ ។ ដើម្បីរក្សាបាននិរន្តរភាពនៃការអភិវឌ្ឍប្រព័ន្ធធនាគារ ធនាគារជាតិនៃកម្ពុជា បានលើកកម្ពស់ជាប្រចាំនូវសមត្ថភាពនិងវិធីសាស្ត្រត្រួតពិនិត្យ ការពង្រឹងក្របខ័ណ្ឌច្បាប់និងបទប្បញ្ញត្តិ និងការវិភាគពីហានិភ័យសំខាន់ៗ ដូចជា ហានិភ័យឥណទាន ហានិភ័យសន្ទនីយភាព ហានិភ័យទីផ្សារ និងហានិភ័យប្រតិបត្តិការ ក្នុងគោលបំណងតាមដាននិងពិនិត្យអំពីផលប៉ះពាល់នៃហានិភ័យទាំងនោះ មកលើប្រាក់ចំណេញ និងស្ថានភាពដើមទុនរបស់ប្រព័ន្ធធនាគារ ។

៣/- **វិស័យមីក្រូហិរញ្ញវត្ថុ** : មានការរីកចម្រើនជាបន្តបន្ទាប់ ។ ឥណទានផ្តល់ដោយវិស័យមីក្រូហិរញ្ញវត្ថុបានបន្តកើនឡើងគួរឱ្យកត់សម្គាល់ ដោយសមតុល្យឥណទានសរុប